# គណបក្ស សម រង្ស៊ី

SAM RAINSY PARTY
PARTI SAM RAINSY

សីលធម៌ សច្ចធម៌ យុត្តិធម៌


# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តន៍ការងារគណបក្សសំរាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់

ដើម្បីឲ្យគណបក្សមានភាពរីកចំរើន រឹងមាំ ហើយធានានូវជ័យជំនះក្នុងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សសូមឲ្យប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង សហការជាមួយប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ អនុវត្តនូវការងារដូចតទៅ :

-ជំរុញការងារកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋានក្នុងស្មារតីទទួលខុសត្រូវ អោយបានដល់ទីបញ្ចប់ ហើយទទួលបានលទ្ធផលល្អប្រសើរ

-រៀបចំផែនការសកម្មភាពសំរាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧

## I-ការងារកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋាន

ការចុះបញ្ជីសមាជិកគណបក្សតាមភូមិ ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណបក្សភូមិ និងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ គឺជាការងារចំបងរបស់គណបក្ស ដែលប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវក្នុងស្មារតីទទួលខុសត្រូវ ស្របតាមសេចក្តីណែនាំស្តីពីនីតិវិធី និងទំរង់បែបបទ នៃការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណបក្សភូមិ ឃុំ-សង្កាត់ ស្រុក-ខណ្ឌ និងខេត្ត-ក្រុង ។

លទ្ធផលកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋានសំរាប់ខេត្ត-ក្រុងនីមួយៗ ក៏ដូចជាសំរាប់ស្រុក-ខណ្ឌនីមួយៗផងដែរ ដែលត្រូវបានទទួលស្គាល់ថាល្អប្រសើរ គឺខេត្ត-ក្រុង ឬស្រុក-ខណ្ឌណាដែលបានចុះបញ្ជី និងធ្វើប័ណ្ណសមាជិកគណបក្សបានចំនួនច្រើនជាងគេ ធៀបនឹងចំនួនប្រជាពលរដ្ឋសរុបនៅក្នុងខេត្ត-ក្រុង ឬស្រុក-ខណ្ឌនោះ ។

លទ្ធផលនៃកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋាននេះ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សនឹងយកធ្វើជាមូលដ្ឋានចំបងក្នុងការវាយតម្លៃអំពីប្រសិទ្ធភាពការងារគណបក្សនៅក្នុងខេត្ត-ក្រុង ឬស្រុក-ខណ្ឌសាមី ។

## II-ការងាររៀបចំសំរាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់

ដើម្បីធានានូវជ័យជំនះក្នុងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវរៀបចំផែនការសកម្មភាពការងារជាក់ស្តែងសំរាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលផ្តោតជាពិសេសទៅលើ :

១-ជំរុញ និងជួយធ្វើអន្តរាគមន៍ដើម្បីឲ្យប្រជាពលរដ្ឋនៅតាមភូមិនីមួយៗបានធ្វើអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា


ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org

២_បណ្តុះបណ្តាលចំណេះដឹងអំពីតួនាទី និងភារកិច្ចដល់ក្រុមប្រឹក្សាគណបក្សភូមិ

៣_ត្រៀមលក្ខណៈ និងជំរុញឲ្យបានខ្លាំងក្លាក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦ ក្នុងឃុំ-សង្កាត់នីមួយៗ ពិសេសសំរាប់ឃុំ-សង្កាត់ជាអាទិភាព

៤_ការជ្រើសរើសបេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់

៥_ការជ្រើសរើស និងបណ្តុះបណ្តាលភ្នាក់ងារគណបក្ស

៦_ការងារយុទ្ធនាការឃោសនារកសម្លេងឆ្នោត រយះពេល១៥ថ្ងៃ

៧_ត្រៀមលក្ខណៈ និងជំរុញប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតឲ្យទៅបោះឆ្នោតគ្រប់គ្នា នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧

៨_វិធានការការពារសន្លឹកឆ្នោតនៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដោយស្វែងរកថវិកា និងប្រមែប្រមូលធនធានមនុស្សនៅក្នុងជួរសកម្មជនគណបក្សទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីចាត់ចែង និងអនុវត្តនូវផែនការសកម្មភាពការងារទាំងអស់នេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ និងធានានូវជ័យជំនះក្នុងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស នឹងយកលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០៧នៅក្នុងខេត្ត-ក្រុងនីមួយៗ ធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃអំពីប្រសិទ្ធភាពការងារគណបក្សនៅក្នុងខេត្ត-ក្រុងនោះ ។

ឧទាហរណ៍ : ក្នុងករណីនៅទូទាំងប្រទេស ចំនួនសន្លឹកឆ្នោតរបស់គណបក្ស សម រង្ស៊ី នៅឆ្នាំ២០០៧ កើន ៥០ % ធៀបនឹងចំនួនសន្លឹកឆ្នោតទទួលបាននៅឆ្នាំ២០០២ :

_បើនៅក្នុងខេត្ត-ក្រុងណាមួយ ចំនួនសន្លឹកឆ្នោតដែលគណបក្ស សម រង្ស៊ី ទទួលបាននៅឆ្នាំ២០០៧ តិចជាង៥០ % ធៀបនឹងចំនួនសន្លឹកឆ្នោតទទួលបាននៅឆ្នាំ២០០២ បានន័យថា ការដឹកនាំគណបក្សនៅក្នុងខេត្ត-ក្រុងនោះមានភាពអន់ខ្សោយ ។ ករណីនេះ ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះ មិនត្រូវបានអនុញ្ញាតឲ្យឈរឈ្មោះជាបេក្ខជនសំរាប់តំណែងប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងនោះតទៅទៀតឡើយ ។

_លទ្ធផលនេះ ក៏យកទៅអនុវត្តសំរាប់វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សកម្មជនគណបក្ស ដែលជាប្រធានក្រុមទ្រទ្រង់ការងារគណបក្សប្រចាំស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ ដែលមានបំណងឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ។

ប្រធានក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៦

ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

សម រង្ស៊ី